# ៥. រឿងព្រះមហាកស្សបត្ថេរ

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមហាកស្សបៈ ត្រាស់ព្រះធម្មទេសនានេះថា បមាទំ អប្បមាទេន "... សេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ" ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះថេរៈគង់នៅក្នុងបិប្ផលិគុហា ត្រាច់ទៅបិណ្ឌបាត ខាងក្រោយកត្តគង់ចម្រើនអាលោកកសិណ ពិចារណាមើលសត្វទាំងឡាយដែលប្រមាទ និងមិនប្រមាទ ដែលកំពុងស្លាប់ និងដែលកំពុងកើតក្នុងទីទាំងឡាយ មានទឹក ផែនដី និងភ្នំជាដើម ដោយទិព្វចក្ខុ ។ ព្រះសាស្តាទ្រង់ប្រថាប់នៅក្នុងវត្តជេតពននោះឯង ទ្រង់ពិចារណាមើលដោយទិព្វចក្ខុថា "ថ្ងៃនេះ កស្សបៈបុត្តរបស់តថាគត នៅដោយវិហារធម៌អ្វីហ្ន៎" ទ្រង់ជ្រាបថា "កំពុងពិចារណាមើលនូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ" ទើបត្រាស់ថា "ដែលឈ្មោះថា ការចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ប្រសិនបើពុទ្ធញ្ញាណមិនកំណត់ហើយ នរណាៗ ក៏មិនអាចនឹងធ្វើការកំណត់ដឹងសត្វទាំងឡាយដែលបដិសន្ធិក្នុងផ្ទៃនៃមាតា ដែលមាតាបិតាមិនទាន់បានដឹង ក៏ចុតិហើយបាន ការដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងនោះ មិនមែន

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.028_att

វិស័យរបស់អ្នកទេ ម្នាលកស្សបៈ វិស័យរបស់អ្នកមានប្រមាណតិច ឯការដឹង ការឃើញ សត្វទាំងឡាយដែលកំពុងចុតិ និងបដិសន្ធិដោយប្រការទាំងពួងនោះ ជាវិស័យរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ" ដូច្នេះ ហើយទ្រង់ផ្សាយព្រះរស្មីទៅ ហាក់ដូចជាទ្រង់ប្រថាប់នៅក្នុងទីចំពោះមុខ ហើយត្រាស់ព្រះគាថានេះថា ៖

បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ
បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនី បជំ
បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។

កាលណា បណ្ឌិតបន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទ គឺ បញ្ញា ជាបុគ្គលមិនសោក រមែងឃើញនូវសត្វដែលមានសោក ធីរជន តែងឃើញពួកជនពាលដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលនៅលើផែនដី ដូច្នេះឯង ។

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.028_att

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.028_att

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា នុទតិ (បន្ទោបង់) ជាដើម សេចក្ដីថា កាលណាបណ្ឌិតចម្រើនកពូនទូវអប្បមាទលក្ខណៈ មិនឲ្យឱកាសដល់សេចក្ដីប្រមាទ ឈ្មោះថា បន្ទោបង់ គឺ រមែងបណ្ដេញបង់នូវសេចក្ដីប្រមាទនោះ ដោយកម្លាំងនៃសេចក្ដីមិនប្រមាទ ដូចទឹកថ្មីដែលហូរចូលកាន់ស្រះបោក្ខរណីញ៉ាំងទឹកចាស់ឲ្យខ្ចាត់ចេញហើយ មិនឲ្យឱកាសដល់ទឹកចាស់នោះ រមែងប្រាទចេញ គឺ រមែងញ៉ាំងទឹកចាស់នោះឲ្យហូរចេញទៅ ដោយទីបំផុតនៃខ្លួន ដូច្នេះ ។ កាលនោះ បណ្ឌិតនោះ មានសេចក្ដីប្រមាទដែលបន្ទោបង់ហើយ បំពេញបដិបទាដ៏សមគួរដល់សេចក្ដីមិនប្រមាទនោះ ឡើងកាន់បញ្ញាដូចជាប្រាសាទ ពោលគឺ ទិព្វចក្ខុដ៏បរិសុទ្ធ ព្រោះអត្ថថា ជាធម្មជាតិដ៏ខ្ពង់ខ្ពស់ក្រៃលែង ដោយបដិបទានោះ ដូចបុគ្គលឡើងកាន់ប្រាសាទតាមកាំជណ្ដើរដូច្នោះ ដែលឈ្មោះថា អ្នកមិនមានសេចក្ដីសោកសៅ ព្រោះភាពជាអ្នកលះបង់នូវកូនសរ គឺ សេចក្ដីសោកចេញបានហើយ រមែងពិចារណាឃើញ គឺ រមែងក្រឡេកឃើញនូវប្រជា គឺ ពពួកសត្វដែលមាននូវសេចក្ដីសោក ព្រោះជាអ្នកលះបង់នូវកូនសរ គឺ សេចក្ដីសោកមិនទាន់បាន ដែលកំពុង

ចុតិ និងបដិសន្ធិដោយទិព្វចក្ខុ ។

សួរថា ដូចអ្វី ?

ឆ្លើយថា ដូចបុគ្គលដែលឈរនៅលើកំពូលភ្នំ រមែងក្រឡេកឃើញបុគ្គលដែលឈរនៅលើផែនដីបាន ដូច្នោះ (បព្វតដ្ឋោវ ភុម្មដ្ឋេ) អធិប្បាយថា បុគ្គលដែលឈរនៅលើកំពូលភ្នំ រមែងមើលឃើញបុគ្គលដែលឈរនៅលើផែនដីបាន ឬបុគ្គលដែលឈរនៅខាងលើប្រាសាទជាន់លើ រមែងមើលឃើញបុគ្គល ដែលឈរនៅក្នុងបរិវេណនៃប្រាសាទបាន ដោយមិនលំបាកយ៉ាងណា អ្នកប្រាជ្ញ គឺ បណ្ឌិត បានដល់ ព្រះមហាខីណាស្រពរូបនោះ ក៏រមែងពិចារណាឃើញបុគ្គលពាលទាំងឡាយ ដែលមានពូជ គឺ វដ្តៈមិនទាន់បានកាត់ផ្តាច់ កំពុងចុតិ និងបដិសន្ធិ ដោយមិនលំបាកដូច្នោះ ។

កាលចប់គាថា ជនជាច្រើន បានធ្វើឲ្យជាក់ច្បាស់ហើយនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងមហាកស្សបត្ថេរ

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.028_att